ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ នាមនាមប្រជារាស្ត្រខ្មែរ

លេខ : ៦២ តុលាការកំពូល

ចុះថ្ងៃទី ០១-០៧-២០០៥

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០៦

លេខ : ០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី ១១-០១-២០០៦

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ប្រធាន |
| ២-លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣-លោក | វៀល | មួន | ចៅក្រម |
| ៤-លោក | យស់ | សូខឿន | ចៅក្រមរបាយការណ៍ |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ចៅក្រម |

ក្រឡាបញ្ជី

លោក យាង ស្រ៊ុន

តំណាងមហាអយ្យការ

លោក ស៊ិន រិទ្ធ ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ៤១" ជ " ចុះថ្ងៃទី ១៩-០៨-២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៦២ ចុះថ្ងៃទី ០១-០៧-២០០៥ របស់តុលាការកំពូល ។

**ត្រូវចោទពីបទ** : ឆបោកប្រព្រឹត្តនៅភូមិ មេភ្លើង ឃុំ-ស្រុក-ខេត្ត ស្វាយរៀង កាលពីថ្ងៃទី ខែ ១០ ឆ្នាំ ១៩៩៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ជនជាប់ចោទ** : ឈ្មោះ នេត ច័ន្ទមុន្នីរ័ត្ន "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ២៧ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិ ចុងព្រែក ឃុំ-ស្រុក-ខេត្ត ស្វាយរៀង ។ ទីលំនៅសព្វថ្ងៃ ភូមិមេភ្លើង ឃុំ-ស្រុក-ខេត្ត ស្វាយរៀង ។ ប្តីឈ្មោះ វ៉ា សំអិន មានកូន ០៣នាក់ ឪពុកឈ្មោះ នេត ចន "ស" ម្តាយឈ្មោះ រ័ត្ន ហ៊ាន់ "រ" ។ ទោសពីមុនគ្មាន ។

-មេធាវី កញ្ញា មាស សុគន្ធា

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ពុត ម៉ាលី "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៥៤ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិមេភ្លើង ឃុំ-ស្រុក-ខេត្ត ស្វាយរៀង ។ តំណាងដោយឈ្មោះ ស្រី ម៉ាឡា ។

-មេធាវី គ្មាន

-កាលពីខែ តុលា ឆ្នាំ ១៩៩៩ អ្នកគ្រូ ធឹម វិគ្គា បានបបួលលេងតុងទីន ពេលនោះឈ្មោះ នេត ច័ន្ទមុន្នីរត្ន័ លេងមួយឈ្មោះដែរ តែពុំបង់ប្រាក់របស់ខ្លួនទេ ទៅបោកនារី ពុត ម៉ាលី ថា លេងតុងទីនជាមួយក្នុងសាលា ហើយដាក់ឈ្មោះខ្លួនជំនួសឈ្មោះ ពុត ម៉ាលី ។ នៅខែដំបូងឈ្មោះ ពុត ម៉ាលី បានបង់ប្រាក់អោយទៅឈ្មោះ នេត ច័ន្ទមុន្នីរត្ន័ ចំនួន ៥០.០០០រៀល តែឈ្មោះនេះពុំបានយកទៅបង់អោយមេតុងទីនទេ ។ លុះបន្តបន្ទាប់មកទៀត នារី ពុត ម៉ាលី បានផ្ញើប្រាក់តុងទីនបង់អោយមេតុងទីនទៀត តែត្រូវឈ្មោះ នេត ច័ន្ទមុនីរត្ន័នេះយកទៅចាយអស់ ហើយត្រូវមេតុងទីនលប់ឈ្មោះនេះចេញពីបញ្ជីតុងទីន ហើយនារី នេត ច័ន្ទមុនីរត្ន័បានទៅយកប្រាក់តុងទីនពី ពុត ម៉ាលី ជារៀងរាល់ខែ រហូតដល់ទៅ១៨ខែទើបបែកការ នារី ពុត ម៉ាលី ទៅសួរមេតុងទីន និងទៅសួរ នេត ច័ន្ទមុន្នីរត្ន័ និយាយថា មិនស្គាល់ឈ្មោះ ពុត ម៉ាលី នេះទេ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការខេត្តស្វាយរៀងសំរេច : ចោទប្រកាន់លើឈ្មោះ នេត ច័ន្ទមុន្នីរត្ន័ អាយុ ២៧ឆ្នាំ ភេទស្រី ជាតិ ខ្មែរ មុខរបរ គ្រូការិយាល័យអប់រំស្រុកស្វាយរៀង ។ ឪពុកឈ្មោះ នេត ចុន "ស" ម្តាយឈ្មោះ រត្ន័ ហ៊ាន់ "រ" ប្តីឈ្មោះ វ៉ា សំអិន មានកូន ០៣នាក់ ទោសពីមុនគ្មាន ។

-ពីបទ : ឆបោកទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ប្រព្រឹត្តនៅភូមិ មេភ្លើង ឃុំ-ស្រុក-ខេត្ត ស្វាយរៀង កាលពីថ្ងៃទី ខែ ១០ ឆ្នាំ ១៩៩៩ បទល្មើសដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨៨ ចុះថ្ងៃទី ១៣-១២-២០០១ របស់តុលាការខេត្តស្វាយរៀង ដែលមានសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសនារី នេត ច័ន្ទមុន្នីរត្ន័ ដាក់ពន្ធនាគារកំណត់ ០១ ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅពីបទ : ឆបោកទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ប្រព្រឹត្តនៅភូមិមេភ្លើង ឃុំ-ស្រុក-ខេត្ត ស្វាយរៀង កាលពី ថ្ងៃទី ខែ ១០ ឆ្នាំ ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយឈ្មោះ នេត ច័ន្ទមុន្នីរត្ន័ សងសំណងប្រាក់ដែលឆបោក និងជំងឺចិត្តទៅឈ្មោះ នារី ពុត ម៉ាលី ដើមបណ្តឹងរដ្ឋប្បវេណីគឺ :

-ប្រាក់ដែលឆបោក ចំនួន ៨២៤.០០០រៀល

-ជំងឺចិត្ត ចំនួន ១.០០០.០០០រៀល

-សរុបទាំងអស់ចំនួន១.៨២៤.០០០រៀល មួយលានប្រាំបីសែនពីរម៉ឺនបួនពាន់រៀលគត់ សំណើលើសពីនេះត្រូវលើកចោល ។

បើពុំមានប្រាក់សងគ្រប់ចំនួនទេ ត្រូវអនុវត្តមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ

គឺ : $\dfrac{\text{១ ថ្ងៃ គុណ ១០០.០០០}}{\text{៥០០}}$ បូក $\dfrac{\text{១ ថ្ងៃ គុណ ១.៧២៤.០០០}}{\text{១០០០}}$ ស្មើ ១.៩២៤ថ្ងៃ ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣៤ ចុះថ្ងៃទី ២៥-១២-២០០១ របស់ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ដែលតវ៉ាមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ ៨៨ ចុះថ្ងៃទី ១៣-១២-២០០១ របស់តុលាការខេត្តស្វាយរៀង លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍សំរេច :

១-ទទួលពាក្យបណ្តឹងតវ៉ាលេខ ៣៤ ចុះថ្ងៃទី ២៥-១២-២០០១ របស់ជនជាប់ចោទឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្នុំយគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៨ ចុះថ្ងៃទី ១៣-១២-២០០១ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤១ " ជ " ចុះថ្ងៃទី ១៩-៨-២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥-១២-២០០១ របស់ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ នឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី ១៣-១២-២០០១ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងមេធាវី មាស សុគន្ធា និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខតាមបណ្តឹងលេខ ១១០ ចុះថ្ងៃទី ២០-០៩-២០០៤ របស់ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ដែលប្តឹងតវ៉ាមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៤១ " ជ " ចុះថ្ងៃទី ១៩-០៨-២០០៤ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ធ្វើឡើងតាមកំណត់ ច្បាប់ ។

-បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូល ឡើងសន្និដ្ឋាននាពេលសវនាការថា : ករណីរឿងនេះសាលាឧទ្ធរណ៍សំរេចក៏ពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ ពីព្រោះជនជាប់ចោទមិនមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកពីបទ ឆបោកដែរ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និងសំរេច ។

-បានស្តាប់ក្រឡាបញ្ជី អានសាវតាជាតិ និងសារណារបស់ជនជាប់ចោទ ។

-បានស្តាប់សាវតាជាតិ និងចំលើយអះអាងរបស់ឈ្មោះ ស្រី ម៉ាឡា តំណាងឱ្យដើមបណ្តឹងនាពេលសវនាការថា : ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ជាអ្នកបបួលម្តាយខ្ញុំលេងតុងទីន តែគាត់បានឈប់លេងហើយ ឈ្មោះនេះនៅតែយកប្រាក់ដែលគាត់ផ្ញើឱ្យទៅបង់រាល់ខែ ។ មានបញ្ជីឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ សូម្បីនាងខ្ញុំជាកូនដឹងដែរ ពីព្រោះប្រាក់ដែលម្តាយខ្ញុំផ្ញើឱ្យទៅឈ្មោះនោះមានរយៈពេល ៨ខែ ហើយដោយទុកចិត្តនិងស្គាល់គ្នា ផ្ទះនៅជិតគ្នា ។ ពេលចូលឆ្នាំត្រូវទៅដេញ ហើយមេប្រាំកែកមិនព្រម

ទទួលស្គាល់ ទើបដឹងថាឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន អ្នកយកលុយទៅលេង បែរជាមិនបានទទួល ឬ បបួលលេងតុងទីនទៅវិញ។ សូមសំណូមពរដោះស្រាយតាមច្បាប់។

-បានស្តាប់មេធាវី កញ្ញា មាស សុគន្ធា ខាងឡើងមានយោបល់នាពេលសវនាការថា : ខ្ញុំមិនអាចការពារឱ្យបានទេ ពីព្រោះជនជាប់ចោទអវត្តមាន និងជិតទាស់នីតិវិធីនេះ។

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូល ពុំមានអ្វីសន្និដ្ឋានបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកនៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍.

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ.

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និងចំលើយរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋាន របស់មេធាវីជនជាប់ចោទ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១១០ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្តស្វាយរៀងដែរ ដែលបានសំរេចផ្តន្ទាទោសលើឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន ពីបទឆបោកនោះគឺពុំទាន់មានភស្តុតាងគ្រប់គ្រាន់ ឬ ឯកសារណាមួយបញ្ជាក់ថាឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន ប្រើកលល្បិចបញ្ឆោតដើម្បីយកប្រាក់ពីឈ្មោះ ពុត ម៉ាលី ទៅលេងតុងទីនជំនួសនោះឡើយ ម្យ៉ាងទៀតតាមបញ្ជីឈ្មោះអ្នកលេងតុងទីនដែលមានឈ្មោះ ធឹម វត្ថា ជាមេនោះគឺពុំឃើញមានឈ្មោះ ពុត ម៉ាលី ទេ ឯនៅត្រង់ឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន គឺមានការសរសេរបន្ថែម និងលុបវិញដោយទឹកខ្មៅពណ៌ក្រហម និងមានកែបន្ថែមចំនួនសមាជិក និងខែនៃថ្ងៃកើបចុងក្រោយ។

-យល់ឃើញថា ពុំមានភស្តុតាងណាមួយបញ្ជាក់ពីពិរុទ្ធភាពរបស់អ្នកស្រី នេត ចន្ទ័មុន្នីរ័ត្ន ថាបានប្រើកលល្បិចធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្រគល់ប្រាក់ឱ្យខ្លួន ក្រៅពីចំលើយសាក្សីដែលជាកូនរបស់ដើមចោទតែប៉ុណ្ណោះដែលពុំគប្បីតុលាការលើកយកមកពិចារណាទេ ដូចនេះគប្បីតុលាការកំពូលសំរេចតាមការកំណត់នៃមាត្រា ២២២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលលោកស្រីមេធាវីជនជាប់ចោទលើកឡើងថា លោកស្រីពុំអាចធ្វើការការពារកូនក្តីលោកស្រីដោយអវត្តមានកូនក្តីបានទេ ហើយក៏ទាស់នឹងនីតិវិធីនៃសវនាការនេះ នោះតុលាការពុំអាចពិចារណាទេ ពីព្រោះថានៅតុលាការអង្គច្បាប់ សារណារបស់ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកជាវត្តមានរបស់អ្នកទាំងនោះហើយ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ នេត ចន្ទ័មុន្នីរ័ត្ន បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួន ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤១ "ជ " ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ដែលបាន សំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខតំណាង**

**ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ១១០ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ នេត ចន្ទ័មុន្នីរត្ន័ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៤១"ជ" ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣-អោយអ្នកស្រី នេត ចន្ទ័មុន្នីរត្ន័ រួចផុតពីការចោទប្រកាន់ពីបទ ឆបោកប្រព្រឹត្តនៅភូមិមេភ្លើង ឃុំ-ស្រុក-ខេត្តស្វាយរៀង តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦ ។ ៚